United Nations
Educational, Scientific and
Cultural Organization

Organisation
des Nations Unies
pour l'éducation,
la science et la culture

# សេចក្ដីប្រកាសព័ត៌មាន

ពិធីសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ស្ដីអំពី

«មរតកយើងទាំងអស់គ្នា៖ ស្វែង យល់អំពីរមណីយដ្ឋាន បេតិកភណ្ឌលោកនៅប្រទេស កម្ពុជា ឡាវ និង វៀតណាម»

នៅសារមន្ទីរជាតិកម្ពុជា នាថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ២០១៣ វេលាម៉ោង ៥រសៀល

ពិធីសម្ពោធពិព័រណ៍មិនអចិន្ត្រៃយ៍ស្ដីអំពី «មរតកយើងទាំងអស់គ្នា៖ ស្វែងយល់អំពីរមណីយដ្ឋានបេតិកភណ្ឌលោកនៅប្រទេស កម្ពុជា ឡាវ និងវៀតណាម» ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៣ នៅសារមន្ទីរជាតិកម្ពុជានេះគឺជាសមិទ្ធផលនៃគម្រោងស្ដីអំពី «ការធ្វើឲ្យរស់រានជីវិតឡើងវិញនូវសារមន្ទីរតាមរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅប្រទេស កម្ពុជា ឡាវ និងវៀតណាម» ដែលឧបត្ថម្ភថវិកាដោយរដ្ឋាភិបាលជប៉ុនតាមរយៈអង្គការយូណេស្កូ។ គម្រោងនេះចាប់ផ្ដើមឡើងតាំងពីខែកក្កដា ឆ្នាំ២០១១ និងមានសិក្ខាសាលាចំនួនពីរលើកត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌគម្រោងនេះផងដែរ។ សិក្ខាសាលាទីមួយបានរៀបចំឡើងនៅទីក្រុងហាណូយនៃប្រទេសវៀតណាមក្នុងឆ្នាំ២០១១និង សិក្ខាសាលាទីពីរបានធ្វើនៅខេត្តសៀមរាបនៃប្រទេសកម្ពុជាក្នុងឆ្នាំ២០១២។ សិក្ខាសាលាទាំងពីរលើកនោះមានសមាជិកមកពីសារមន្ទីរចំនួនប្រាំបួនចូលរួម។ សារមន្ទីរបួននៃប្រទេសកម្ពុជាគឺ សារមន្ទីរជាតិកម្ពុជា សារមន្ទីរព្រះនរោត្តមសីហនុអង្គរ សារមន្ទីរជាតិអង្គរ និងសារមន្ទីរធម្មជាតិសកលសម្ដេចតេជោហ៊ុនសែន។ សារមន្ទីរបួនផ្សេងទៀតនៃប្រទេសវៀតណាមគឺ មណ្ឌលអភិរក្សបេតិកភណ្ឌពិភពលោកថាងឡុង, សារមន្ទីរដាណាងអំពីចម្លាក់ចាម, គណៈគ្រប់គ្រងបេតិកភណ្ឌពិភពលោកមុីសឺន និងមណ្ឌលអភិរក្សបន្ទាយហ្វេ និងសារមន្ទីរវត្តភូនៃប្រទេសឡាវ។

ពិព័រណ៍ស្ដីអំពី«មរតកយើងទាំងអស់គ្នា៖ ស្វែងយល់អំពីរមណីយដ្ឋានបេតិកភណ្ឌពិភពលោកនៅប្រទេសកម្ពុជា ឡាវ និងវៀតណាម»នេះ នឹងដាក់តាំងនៅតាមសារមន្ទីរទាំងប្រាំបួនដែលបានរៀបរាប់ខាងលើ។ ចំពោះប្រទេសកម្ពុជា នេះគឺជាលើកទីពីរនៃការសម្ពោធពិព័រណ៍បែបនេះ។ ការសម្ពោធដំបូងបានប្រព្រឹត្តិទៅនៅសារមន្ទីរព្រះនរោត្តមសីហនុអង្គរនៅខេត្តសៀមរាបកាលពីខែធ្នូ ឆ្នាំ២០១២កន្លងទៅនេះ។ ការសម្ពោធពីរផ្សេងទៀតនឹងធ្វើឡើងនៅសារមន្ទីរជាតិអង្គរ និងសារមន្ទីរធម្មជាតិសកលសម្ដេចតេជោហ៊ុនសែនក្នុងឆ្នាំ២០១៣នេះផងដែរ។

ពិព័រណ៍នេះមានផ្ទាំងព័ត៌មានចំនួនបួនប្រភេទ។ ប្រភេទទីមួយមានប្រធានបទរៀបរាប់អំពីគោលគំនិតនៃអនុសញ្ញាបេតិកភណ្ឌពិភពលោក, ប្រវត្តិទីតាំង និងតម្លៃជាសកលនៃរមណីយដ្ឋានបេតិកភណ្ឌទាំងអស់នោះ។ ប្រភេទទីពីរមានប្រធានបទបង្ហាញអំពីធម្មជាតិនិងទេវកថា។ ប្រភេទទីបីបង្ហាញអំពីពាណិជ្ជកម្មនិងការផ្លាស់ប្ដូរ។ រីឯប្រភេទទីបួនគឺជាក្រុមពិសេសមានប្រធានផ្សេងៗអាស្រ័យតាមសារមន្ទីរនីមួយៗ។ ដោយឡែកសម្រាប់សារមន្ទីរជាតិកម្ពុជានឹងបង្ហាញអំពី «ក្បាច់លម្អខ្មែរ»។

បន្ថែមពីលើពិព័រណ៍នេះទៅទៀត សារមន្ទីរជាតិកម្ពុជាក៏ដូចជាសារមន្ទីរទាំងប្រាំបីផ្សេងទៀតនឹងរៀបចំកម្មវិធីអប់រំដល់សិស្សានុសិស្សរហូតដល់ដំណាច់ខែមិថុនា ឆ្នាំ២០១៣។

គោលបំណងសំខាន់នៃពិព័រណ៍នេះ គឺដើម្បីបង្ហាញពីទំនាក់ទំនងគ្នាជាប្រវត្តិសាស្ត្ររវាងរមណីយដ្ឋានបេតិកភណ្ឌពិភពលោក រួមទាំងប្រជាជនទាំងឡាយដែលរស់នៅក្នុងតំបន់ឥណ្ឌូចិននេះផងដែរ៕